ការសន្មត (presumption) (William Twining and Alex Stein, Evidence and Proof, 1992, pp. 427-451)

**ពាក្យគន្លឹះ÷** ការសន្មត ការបដិសេធ និងបន្ទុកភស្តុតាង

**១.** នៅក្នុងដំណើរការក្តីរឿងព្រហ្មទណ្ឌ ភស្តុតាងជាច្រើនត្រូវបានទាមទារ ហើយដើម្បីសម្រួលនីតិវិធីឲ្យបានលឿន មានការសន្មតលើអង្គហេតុអ្វីមួយថាពិត រហូតដល់មានភស្តុតាងផ្ទុយ។ ការសន្មតផ្តើមពីអង្គហេតុចម្បង (basic fact) ឈានទៅអង្គហេតុសន្មត (presumed facts) ដែលអាចបង្កប់នូវភាពមិនពិតឬលម្អៀង។ ដូចនេះ ការសន្មត មិនមានភាពដាច់ខាតទេ (mandatory) សុទ្ធតែអាចបដិសេធបាន (rebuttal)។ ការសន្មត អាចជាទូទៅនិងតាមផ្លូវច្បាប់ (legal presumption)។ ការសន្មត មានបីប្រភេទ÷ តាមតម្លៃ តាមការអនុវត្ត និងលទ្ធភាពនៃការកើតឡើង (inductive-probabilistic presumption)

**២.** ការសន្មតនោះមានដូចជា÷ កុមារកើតក្នុងចំណងអាពាហ៍ពិពាហ៍ ជាកុមារស្របច្បាប់ (legitimate)។ បុគ្គលដែលមិនបានពន្យល់សមស្រប និងមិនត្រូវបានគេដឹងលីរយៈពេល៧ឆ្នាំ ត្រូវបានសន្មតថាស្លាប់។ ការរៀបការ បើត្រូវបានប្រកាសជាឪឡារិក មានសុពលភាព។ កុមារអាយុក្រោម១៤ឆ្នាំ មិនមានចេតនាព្រហ្មទណ្ឌ។ បើបុគ្គល **ក** ទិញទ្រព្យសម្បត្តិពីបុគ្គល **ខ** នឹងផ្តោតដល់បុគ្គល **គ**។ បុគ្គល **គ** ត្រូវបានសន្មតថាជាអ្នកគ្រប់គ្រងសម្រាប់បុគ្គល **ក**។ បុគ្គលត្រូវបានចោទពីបទឧក្រិដ្ឋ ត្រូវបានសន្មតជាមុនថាមិនមានទោស (innocent)។ មនុស្សគ្រប់គ្នា ត្រូវបានសន្មតថាមិនឆ្កួត។...

**៣.** គេអាចដឹងថា វាជាឃ្លាសន្មត ដោយពិនិត្យមើលពាក្យពេចន៍ ដូចជាពាក្យ «រហូតដល់...... ”។ ការសន្មត មានភាពខ្លាំងឬខ្សោយពេលខ្លះ ផ្អែកតាមលទ្ធភាពនៃការកើតមានដូចការសន្មត (probability)។ ការសន្មត ក៏ត្រូវមានយុត្តិកម្ម ឬហេតុផលផងដែរ។ ទោះបីជាយ៉ាងនេះក្តី ដូចបានអះអាងខាងលើ គ្រប់ការសន្មត មិនមានភាពដាច់ខាតឥតខ្ចោះ១០០ភាគរយទេ។ វាអាចត្រូវបានបដិសេធ (rebuke) ហើយភាគីដែលបដិសេធ ជាអ្នកមានបន្ទុកភស្តុតាង។

............................

ការសន្មតជាមុនថាមិនទាន់មានទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ជាការសន្មតតាមច្បាប់ (legal presumption)។ វាមានចែងក្នុងមាត្រាច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ មាត្រា៣៨។ ដំណើរការកាត់សេចក្តី ត្រូវការពេលវេលាយូរ ក្នុងពេលនោះ អាចមានវិការៈដែលប៉ះដល់សិទ្ធិរបស់បុគ្គលកើតឡើង ហើយដែលមិនអាចជួសជុលបាន។ ក្នុងដំណើរការក្តី បុគ្គលមានសិទ្ធិសុវត្ថិភាពបុគ្គល ដែលនេះជាសិទ្ធិ ហើយការដាក់ឃុំខ្លួនជាបណ្តោះអាសន្ន ជាការកម្រិតសិទ្ធិដែលត្រូវតែជាវិធានលើកលែង។ គេអាចអះអាងថា លទ្ធភាព ឬចំនួននៃការកាត់សេចក្តីខុស មានភាគរយតិច។ ការចែងអំពីការសន្មតនេះ ពាក់ព័ន្ធនឹងតម្លៃបុគ្គល (value based presumption)។ ការសន្មតនេះ នាំឲ្យបានការប្រព្រឹត្ត នាំឲ្យកាត់បន្ថយកំហុស ឬជៀសវាងកំហុសជាយថាហេតុបាន។ ជាការឆ្លើយតប វាទាមទារនូវកម្រិតភស្តុតាងខ្ពស់ ដើម្បីបដិសេធនូវការសន្មត។ នេះដូចគ្នានឹង ការសន្មតមានសេរីភាព (presumption of liberty) ឬការសន្មតថាមិនមានភាពលម្អៀង (presumption of impartiality) ប្រើសម្រាប់ទាត់ចោលបណ្តឹងជិតចិត្ត ដែលភាគីប្តឹង ត្រូវតែមានភស្តុតាងរឹងមាំដើម្បីបដិសេធការសន្មតនេះ។